ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ.០.១៨.សរ.សរ...../គ.ជ.អ.ប

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការត្រៀមរៀបចំកិច្ចការនានាសម្រាប់ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមការសម្រេចរបស់ គ.ជ.អ.ប ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩

# សម្រេច

**ប្រការ ១.-**

ត្រូវបង្កើតគណៈកម្មការមួយ ដើម្បីដឹកនាំការត្រៀមរៀបចំកិច្ចការនានាសម្រាប់ការផ្ទេរសិទ្ធិ និងការ

ទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្នទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **ម៉ុន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **ទេព នន្ទី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- លោកជំទាវ **ឃឹម ចំរើន** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ៦- ឯកឧត្តម **តែ គុយសាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧- ឯកឧត្តម **ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៨- ឯកឧត្តម **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- ឯកឧត្តម **គីម ទូច** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០- ឯកឧត្តម **ចាន់ សារុណ្ណ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- លោកជំទាវ **ដាំ ដារីន្ទ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- ឯកឧត្តម **ណាក សាខន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- ឯកឧត្តម **រស់ សុផាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១៤- ឯកឧត្តម **លេង ទី** | អគ្គនាយករដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះ មានភារកិច្ចដឹកនាំ ណែនាំ សម្របសម្រួលក្នុងដំណើរការត្រៀមរៀបចំកិច្ចការនានាសម្រាប់ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្នទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១ ស្របតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប លេខ ០១៧ ស.ណ.ន/គ.ជ.អ.ប ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០០៩។

**ប្រការ ៣.-**

គណៈកម្មការមានសិទ្ធិបង្កើតក្រុមការងារនានាតាមការចាំបាច់។

**ប្រការ ៤.-**

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចផ្តល់ការគាំទ្រផ្នែកលេខាធិការដ្ឋាន ការគាំទ្រខាងមធ្យោបាយ សម្ភារៈ ថវិកា និងការគាំទ្រផ្សេងៗទៀតក្នុងកិច្ចដំណើរការរបស់គណៈកម្មការ។

**ប្រការ ៥.-**

អនុប្រធាន និងសមាជិកគណៈកម្មការត្រូវចូលរួមប្រជុំ និងបំពេញការងារតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៦.-**

គណៈកម្មការត្រូវបញ្ចប់ភារកិច្ចរបស់ខ្លួនបន្ទាប់ពីកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១។

**ប្រការ ៧.-**

ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប លេខាធិការដ្ឋាននៃ គ.ជ.អ.ប ឯកឧត្តម លោកជំទាវ ដូចមានឈ្មោះក្នុងប្រការ១ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

ស ខេង

<u>**កន្លែងទទួល :**</u>

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧*
- *ឯកសារ កាលប្បវត្តិ*